

# ព័ត៌មានខ្លេយតុន

ខែ តុលា ឆ្នាំ ២០១០

អាសយដ្ឋាន 270 Clayton Road, Clayton. PO Box 5019, Clayton, Victoria 3168
ទូរស័ព្ទ: 03 9543 6081 ទូរសារ: 03 9562 8872 គេហទំព័រ: www.honglimmp.com

## ការស្វាគមន៍ពីលោក ហុង លីម

ក្នុងឋានៈជាសមាជិកសភាតំបន់ខ្លេយតុននិងជាទីប្រឹក្សាពិសេសជូនរដ្ឋមន្ត្រីទី១អំពីទំនាក់ទំនងពាណិជ្ជកម្មវិចតូរីយ៉ា-អាស៊ី ខ្ញុំសូមស្វាគមន៍និងសូមអញ្ជើញបងប្អូនអានព្រឹត្តិប័ត្រព័ត៌មានខ្លេយតុននេះដោយរីករាយ។




បុគ្គលិក និងអ្នកស្ម័គ្រចិត្តទាំងអស់ ព្រមទាំងរូបខ្ញុំផ្ទាល់អាចផ្តល់សេវាបម្រើជូនបងប្អូននូវការងារទាំងឡាយណាដែលទាក់ទងនឹងរដ្ឋាភិបាលរដ្ឋវិចតូរីយ៉ាដូចជា ការផ្តល់ព័ត៌មានអំពីការសិក្សាអប់រំ កម្មវិធីជំនួយថវិកាពីរដ្ឋាភិបាល សេវាសុខភាព កិច្ចការបម្រើសហគមន៍ ព័ត៌មានសម្រាប់មនុស្សចាស់ ច្បាប់និងបទបញ្ញត្តិផ្សេងៗ កម្មវិធីរដ្ឋាភិបាលនិងព័ត៌មានអំពីលំនៅស្ថានរដ្ឋជាដើម ។ ទន្ទឹមនឹងនេះ យើងខ្ញុំក៏អាចជួយលើសេវាកម្មមួយចំនួនទៀតដូចជាការដាក់ពាក្យសុំជំនួយថវិកាពីរដ្ឋ ការរៀបចំប័ណ្ណកិត្តិយសសម្រាប់ពិធីបុណ្យខួបកំណើត អាពាហ៍ពិពាហ៍ និងវត្តអនុស្សាវរីយ៍ផ្សេងៗ ព្រមទាំងជួយលើកឡើងនូវបញ្ហាណាមួយតាមសំណូមពររបស់បងប្អូនទៅកាន់សភាក្នុងពេលអង្គប្រជុំ និងធ្វើជាតំណាងបងប្អូនទៅជួបជជែកពិភាក្សាជាមួយរដ្ឋមន្ត្រីពាក់ព័ន្ធ និងអាចជួយក្នុងកិច្ចការជាច្រើនទៀតផងដែរ៕

## មជ្ឈមណ្ឌលសហគមន៍ខ្លេយតុន (Clayton Community Centre)

មជ្ឈមណ្ឌលសហគមន៍ខ្លេយតុន ឬ Clayton Community Centre គឺជាមជ្ឈមណ្ឌលសហគមន៍ដែលថ្មី និងទំនើបបំផុត ហើយក៏ធំជាងគេបំផុតក្នុងរដ្ឋវិចតូរីយ៉ានេះដែរ ។ ថវិកាចំនួន២៤លាន២សែនដុល្លារ ត្រូវបានដាក់បញ្ចូលក្នុងការស្ថាបនាមជ្ឈមណ្ឌលនេះដែលក្នុងនោះ City of Monash បានចូលរួមថវិកាជាង១៦លានដុល្លារ រួមទាំងថវិកាចំនួនជាង ៨លានដុល្លារទៀតទទួលបានមកពីរដ្ឋាភិបាលរដ្ឋវិចតូរីយ៉ា ។ លោក **ហុង លីម** បានសំដែងនូវមោទនភាពយ៉ាងខ្លាំង ដោយទទួលបានជោគ-ជ័យក្នុងការស្នើទៅរដ្ឋាភិបាលរដ្ឋវិចតូរីយ៉ា ដើម្បីជួយថវិកាដ៏ច្រើនក្នុងការសាងសង់សំណង់ដ៏អស្ចារ្យនេះ ។



ប្លង់គំនូររបស់មជ្ឈមណ្ឌលសហគមន៍ខ្លេយតុនទទួលបានជ័យលាភីគួរឲ្យកោតស្ងប់ស្ងែង ។ ប្រជាជនក្នុងតំបន់ក៏ដូចជាភ្ញៀវមកទស្សនាបានបង្ហាញនូវចំណាប់អារម្មណ៍យ៉ាងខ្លាំង និងសំដែងក្តីសាទរចំពោះការបង្កើតមជ្ឈមណ្ឌលសហគមន៍ខ្លេយតុននេះឡើង ។

មជ្ឈមណ្ឌលសហគមន៍នេះត្រូវបានរៀបចំឡើងដោយមានជាបណ្ណាល័យសាធារណៈ អាងហែលទឹកប្រវែង២៥ម៉ែត្រ ស្ប៉ាកន្លែងលក់អាហារ កន្លែងហាត់ប្រាណ មណ្ឌលថែទាំសុខភាព កន្លែងមើលថែកុមារ មណ្ឌលផ្តល់សេវាជូនយុវជនយុវនារីនិងក្រុមគ្រួសារ បន្ទប់ សម្តែងសិល្បៈ និងបញ្ចាំងភាពយន្ត ពេទ្យធ្មេញ និងពេទ្យមើលថែទាំសុខភាពសហគមន៍ ព្រមទាំងសេវាកម្មជាច្រើនផ្សេងៗទៀត ៕

## សញ្ញាហាមប្រាមអ្នកដើរលក់ដូរគោះទ្វារតាមផ្ទះ (Do Not Knock Sticker)




ប្រជាជនភាគច្រើនមានការធុញទ្រាន់ចំពោះអ្នកដើរលក់ដែលគោះទ្វារផ្ទះរបស់គាត់ដើម្បីបញ្ចុះបញ្ចូលឲ្យគាត់ទិញនូវទំនិញដែលគាត់គ្មានជំនឿថាជាទំនិញមានគុណភាពល្អ ។ ក្នុងករណីនេះ ដោយផ្អែកទៅតាមច្បាប់ អ្នកដើរលក់នោះត្រូវតែគោរពនិងអនុវត្តតាមគោលការណ៍ដែលបានកំណត់ដូចខាងក្រោម ៖

- បើលោកអ្នកស្នើសុំឲ្យអ្នកដើរលក់នោះចាកចេញ គឺគាត់ត្រូវតែចាកចេញភ្លាម
- អ្នកដើរលក់នោះត្រូវបង្ហាញនូវភស្តុតាង ដែលបញ្ជាក់អំពីអត្តសញ្ញាណរបស់ខ្លួន
- អ្នកលក់នោះមិនត្រូវបានអនុញ្ញាតឲ្យនៅលើសពីមួយម៉ោងឡើយ លុះត្រាណាតែមានការអនុញ្ញាតពីលោកអ្នកជាលាយល័ក្ខអក្សរ
- រាល់ការព្រមព្រៀងទិញលក់ទាំងអស់ជាមួយអ្នកដើរលក់ត្រូវធ្វើឡើងជាលាយល័ក្ខអក្សរ
- លោកអ្នកមានសិទ្ធិលុបចោលកិច្ចព្រមព្រៀងជាមួយអ្នកដើរលក់នោះបាន ក្នុងរយៈពេល១០ថ្ងៃបើសិនជាលោកអ្នកប្តូរចិត្ត ។

Do Not Call Register

It's your call

បើលោកអ្នកមិនចង់ឲ្យអ្នកដើរលក់ទាំងនោះមកគោះទ្វារផ្ទះទេនោះ សូមលោកអ្នកទាក់ទងមកការិយាល័យយើងខ្ញុំ ដើម្បីទទួលបាននូវ Do Not Knock Sticker ឬក្រដាសបិទនៅលើទ្វារមុខផ្ទះ កុំឲ្យគេមកគោះទ្វារ ឬបិទនៅលើរបងឬប្រអប់សំបុត្រជាសញ្ញាប្រាប់អ្នកលក់ទាំងនោះថា លោកអ្នកមិនប្រាថ្នាចង់ទិញទំនិញដើរលក់តាមផ្ទះនោះទេ។ បើគេនៅតែមកគោះទ្វារឬទាក់ទងលោកអ្នកនោះ លោកអ្នកអាចរាយការណ៍ ទៅConsumer Affairs Victoria តាមទូរស័ព្ទលេខ **១៣០០ ៥៥៨ ១៨១** ។
បើលោកអ្នកទទួលការទូរស័ព្ទ ដែលលោកអ្នកមិនចង់បាន រដ្ឋាភិបាលមាន Do Not Call Register ដែលអាចបញ្ឈប់ការហៅចូលទាំងនោះបាន ដោយទូរស័ព្ទទៅលេខ **១៣០០ ៧៩២ ៩៥៨** ៕

## ថវិកាជំនួយពីរដ្ឋាភិបាលគាំទ្រលើសកម្មភាពការងារស្ម័គ្រចិត្ត (VOLUNTEERS SMALL GRANTS)

ក្រុមអ្នកធ្វើការងារស្ម័គ្រចិត្តជាង ៧០ក្រុមទទួលបាននូវទំហំថវិកាចំនួន ២៥៦ ០០០ ដុល្លារ ដើម្បីបន្តកិច្ចការដ៏មានតម្លៃ ដែលអ្នកទាំងនេះបាននិងកំពុងធ្វើនៅតាមសហគមន៍ ។ ថវិកាទាំងនេះ ត្រូវបានប្រកាសផ្តល់ជូនកាលពីថ្ងៃទី ១២ ខែឧសភា ឆ្នាំ ២០១០កន្លងទៅនេះ ដែលជាផ្នែកមួយនៃសប្តាហ៍ជាតិសម្រាប់អ្នកធ្វើការងារស្ម័គ្រចិត្ត ឬ National Volunteer Week ។

លោកស្រីរដ្ឋមន្ត្រី Lily D'Ambrosio ទទួលបន្ទុកផ្នែកអភិវឌ្ឍន៍សហគមន៍ បានមានប្រសាសន៍ថា ជំនួយទ្រង់ទ្រាយតូចសម្រាប់អ្នកធ្វើការងារស្ម័គ្រចិត្តរបស់រដ្ឋវិចតូរីយ៉ានឹងគាំទ្រចំពោះគំនិតច្នៃប្រឌិតជាច្រើន ដើម្បីជំរុញឲ្យមានភាពជិតស្និតក្នុងសហគមន៍ ។

លោកស្រីបានបន្តទៀតថា ជំនួយនេះប្រហែលជាតិចតួចទេ គឺអាចមានកំរិតត្រឹមតែ ៥០០០ដុល្លារប៉ុណ្ណោះ ក៏ប៉ុន្តែវាពិតជាមានសារៈប្រយោជន៍យ៉ាងខ្លាំងចំពោះអង្គការដែលបម្រើសហគមន៍ ហើយគឺអង្គការទាំងនេះហើយដែលជួយឲ្យប្រជាជនជាច្រើនបានរស់នៅក្នុងស្ថានភាពប្រសើរជាងមុន ។

តាមរយៈការសិក្សាស្រាវជ្រាវ បានបង្ហាញឲ្យដឹងថាជនដែលធ្វើការងារស្ម័គ្រចិត្តតែងទទួលបាននូវភាពរីកចម្រើនខាងផ្នែកសុខភាព និងសុខុមាលភាព ។

សម្រាប់ព័ត៌មានបន្ថែមអំពីជំនួយថវិកាពីរដ្ឋ សូមចូលទៅ www.grants.dpcd.vic.gov.au

ឬសូមទាក់ទងមកការិយាល័យលោកតំណាងរាស្ត្រ **ហុង លីម** ៕



ការិយាល័យលោក ហុង លីម
តំណាងរាស្ត្រតំបន់ខ្លេយតុន
**270 Clayton Road**
**PO Box 5019**
**Clayton, Victoria 3168**
ទូរស័ព្ទ: **(03) 9543 6018**
ទូរសារ: **9562 8872**
**hong.lim@parliament.vic.gov.au**
**www.honglimmp.com**

# លោក ហុង លីម និងសហគមន៍




លោកហុង លីម និងលោក John SO ព្រមជាមួយលោក Simon CREAN

ពិធីជប់លៀងភោជនាហារដែលមានឈ្មោះថា Clayton Annual Multicultural Banquet លើកទី១៧ បានប្រារព្ធធ្វើនៅថ្ងៃអាទិត្យ ទី១៩ ខែកញ្ញា ឆ្នាំ២០១០កន្លងទៅនេះ ក្នុងគោលបំណងពង្រឹងពហុវប្បធម៌ ក្នុងសង្គមរដ្ឋវិចតូរីយ៉ា។ ពិធីជួបជុំទទួលទានអាហារពេលល្ងាចដែលរៀបចំដោយលោក **ហុង លីម** បានផ្តល់ឱកាសជូនសហគមន៍មកពីស្ថាប័នផ្សេងៗជួបជុំគ្នា បានស្គាល់គ្នា និងរាប់អានគ្នាទៅវិញទៅមក ។

ក្នុងឆ្នាំនេះ ពិធីជួបជុំទទួលទានអាហារពេលល្ងាចលើកទី១៧បានទទួលការគាំទ្រយ៉ាងសន្ធឹកសន្ធាប់ពីសំណាក់ភ្ញៀវចូលរួមជាង ៦០០នាក់ មកពីជាង២០ជាតិសាសន៍ និងជាតំណាងអង្គការ សហគមន៍ ជាង ១០០ អង្គការ ។

ការប្រារព្ធកម្មវិធីពហុវប្បធម៌ និងចំរុះជាតិសាសន៍ក្នុងរដ្ឋវិចតូរីយ៉ាមានភាពរីកចម្រើនទៅមុខគួរឲ្យកត់សំគាល់ ហើយជឿជាក់ថាពីមួយឆ្នាំទៅមួយឆ្នាំ នឹងកាន់ តែមានភាពប្រសើរជាងមុន៕

# ការបោះឆ្នោតក្នុងរដ្ឋវិចតូរីយ៉ា ឆ្នាំ២០១០

ការបោះឆ្នោតក្នុងរដ្ឋវិចតូរីយ៉ា នឹងត្រូវប្រព្រឹត្តទៅនៅថ្ងៃសៅរ៍ **ទី២៧ ខែវិច្ឆិកា ឆ្នាំ២០១០** ខាងមុខនេះ ។

លោក **ហុង លីម** សូមសំដែងនូវកត្តិភាពកតញ្ញូតាធម៌ចំពោះកាយវិការដ៏សប្បុរសរបស់បងប្អូនទាំងអស់ដែលបានបន្តជួយគាំទ្ររូបលោកតទៅទៀតក្នុងការបោះឆ្នោតក្នុងឆ្នាំនេះ។

> " ការជួយគាំទ្ររបស់បងប្អូន គឺជាការជួយលើកស្ទួយកិត្តិយសរបស់ខ្មែរ ដោយបន្តឲ្យមានតំណាងរាស្ត្រមានដើមកំណើតពីប្រទេសកម្ពុជាតទៅទៀតក្នុងជួររដ្ឋាភិបាលរដ្ឋវិចតូរីយ៉ា។"

ការជួយគាំទ្ររបស់បងប្អូន គឺជាការជួយលើកស្ទួយកិត្តិយសរបស់ខ្មែរ ដោយបន្តឲ្យមានតំណាងរាស្ត្រមានដើមកំណើតពីប្រទេសកម្ពុជាបន្តទៀតក្នុងជួររដ្ឋាភិបាលរដ្ឋវិចតូរីយ៉ា ដែលជាមោទនភាពដ៏ខ្ពង់ខ្ពស់របស់ជាតិសាសន៍ខ្មែរយើង ។

បងប្អូនអាចជួយនៅមុនពេលបោះឆ្នោត ក៏ដូចជានៅថ្ងៃបោះឆ្នោតផងដែរតាមរយៈសកម្មភាពមួយចំនួនដូចជា ជួយឈរចែកប័ណ្ណនៅថ្ងៃបោះឆ្នោត ឬមុននោះពីរសប្តាហ៍ ឬក៏ជួយផ្តួចផ្តើមធ្វើវិភាគទានសម្រាប់ការបោះឆ្នោតនេះ ឬក៏ជួយផ្តល់អាសយដ្ឋានសម្រាប់តាំងរូបថតលោកតំណាងរាស្ត្ររយៈពេលបីសប្តាហ៍មុនការបោះឆ្នោតរហូតដល់ថ្ងៃបោះឆ្នោត ។ យើងខ្ញុំសូមថ្លែងអំណរគុណទុកជាមុននូវការជួយជ្រោមជ្រែងខាងលើ ។ សូមបងប្អូនទាក់ទងមកលោក **ហុង លីម** តាមរយៈទូរស័ព្ទលេខ**៩៥៤៣ ៦០៨១**៕

# លោក ហុង លីម ចូលរួមពិធីខួបកំណើតលោកតា អៀង ញ៉ូរ



លោក **ហុង លីម** ជូនពរលោកតា អៀង ញ៉ូរ

លោក អៀង ញ៉ូរ ព្រឹទ្ធាចារ្យដ៏ឆ្នើមនៃសង្គមខ្មែរក្នុងរដ្ឋវិចតូរីយ៉ា បានប្រារព្ធពិធីចម្រើនព្រះជន្មគម្រប់៨០ឆ្នាំរបស់លោក ជាមួយក្រុមគ្រួសារ បងប្អូន និងញាតិមិត្តកាលពីថ្ងៃសៅរ៍ ទី០៨ ខែឧសភា ឆ្នាំ ២០១០ កន្លងទៅនេះ។

លោកតំណាងរាស្ត្រ **ហុង លីម** បានចូលរួមអបអរសាទរក្នុងកម្មវិធី ដ៏មហោឡារិកនេះ ហើយបានប្រគល់នូវប័ណ្ណកិត្តិយសជូនលោកព្រឹទ្ធាចារ្យ អៀង ញ៉ូរ ដែលនៅក្នុងលិខិតនោះ មានរូបថតអគាររដ្ឋសភាដែលថតតំណាលគ្នា នឹងឆ្នាំកំណើតរបស់លោក អៀង ញ៉ូរ ។

លោក **ហុង លីម** បានមានប្រសាសន៍ជំរាបជូនក្នុងពិធីនោះថា សព្វថ្ងៃនេះសភាយើងមានអាយុកាល ១៥២ឆ្នាំហើយ ដូច្នេះលោកសូមជូនពរលោកអៀង ញ៉ូរ ឲ្យមានសុខភាពល្អ អាយុយឺនយូរដូចអាគារសភានេះ ។៕

លោក ហុង លីម សមាជិកសភាមណ្ឌលខ្លេយតុន

# ការពង្រីកបន្ថែមស្ថានីយ៍រថភ្លើង Westall និង ការបង្កើនសេវាដឹកជញ្ជូនរបស់រថយន្តក្រុង SmartBus

ក្រោមកិច្ចផ្តួចផ្តើមនិងខិតខំប្រឹងប្រែងរបស់លោកតំណាងរាស្ត្រ **ហុង លីម** ជាមួយលោករដ្ឋមន្ត្រីដឹកជញ្ជូនសាធារណៈ Martin Pakula ថវិកាជាង១៥០លានដុល្លារ ត្រូវបានអនុម័តដើម្បីយកមកប្រើប្រាស់ក្នុងការកសាងពង្រីកស្ថានីយ៍រថ-ភ្លើង Westall បន្ថែមពីលើសមត្ថភាពដឹកជញ្ជូននិងសេវាកម្មដែលមានក្នុងពេលបច្ចុប្បន្ន។

ក្នុងការសាងសង់នេះគឺមានបញ្ចូលនូវគម្រោងជាច្រើនដូចជាការសង់បន្ថែមផ្លូវរថភ្លើងថ្មីមួយខ្សែទៀត ការសង់បន្ថែមសំណង់ស្ថានីយ៍ថ្មីមួយទៀតដែលមានPlatform រង់ចាំថ្មី រួមទាំងទីតាំងចំណតរថយន្តថ្មីដែលអាចចតរថយន្តបានជាង ៨០ និងស្ពានអាកាសសម្រាប់អ្នកថ្មើរជើងឆ្លងកាត់ពីលើផ្លូវដែកព្រមជាមួយនឹងការបំពាក់នូវប្រព័ន្ធសុវត្ថិភាពនិងបរិក្ខារចាំបាច់មួយចំនួនទៀតដែលបម្រើដល់អ្នកដំណើរ ហើយគម្រោងទាំងនេះត្រូវបានគិតថានឹងផ្តល់នូវភាពកាន់តែងាយស្រួល និងអត្ថប្រយោជន៍បន្ថែមទៀតដល់អ្នកដំណើរ ក៏ដូចជាប្រជាពលរដ្ឋទាំងអស់ដែលរស់នៅតំបន់ជុំវិញនោះ។

លោក **ហុង លីម** បានបញ្ជាក់ជូនក្នុងថ្ងៃពិនិត្យការដ្ឋានសំណង់កាល ពីខែមករាដើមឆ្នាំនេះថា "ការងារសាងសង់ពង្រីកបន្ថែម ស្ថានីយ៍រថភ្លើង Westall នេះគ្រោងនឹងត្រូវបញ្ចប់នៅខែ មេសា ឆ្នាំ២០១១ខាងមុខ។ "




លោក **ហុង លីម** និងលោករដ្ឋមន្ត្រីដឹកជញ្ជូនសាធារណៈ: Martin Pakula

លើសពីនេះទៅទៀត ការបង្កើនសេវាដឹកជញ្ជូននិង ផ្លូវធ្វើដំណើររបស់រថយន្តក្រុង SmartBus លេខ902 នាពេលថ្មីៗនេះបានផ្តល់នូវ ភាពងាយស្រួលយ៉ាងច្រើន ដល់អ្នកធ្វើដំណើរ ជាពិសេសចំពោះប្រជាពលរដ្ឋ ក៏ដូចជានិស្សិតសាកលវិទ្យាល័យម៉ូណាស្ហដែលរស់នៅតំបន់ Dandenong និង Monash ។ សម្រាប់ព័ត៌មានបន្ថែម លោកអ្នកអាចទាក់ទងមកកាន់ ការិយាល័យលោក **ហុង លីម** ហើយយើងខ្ញុំអាចផ្ញើតារាង ពេលវេលាធ្វើដំណើររបស់រថយន្តក្រុង SmartBus នេះជូន លោកអ្នកបានតាមសំណូមពរ ៕




រូបភាពគូរដោយកុំព្យូទ័របង្ហាញអំពីសំណង់ស្ថានីយ៍រថភ្លើងWestall ថ្មី ដែលមានបំពាក់នូវជណ្តើរយន្តទំនើប បង្កើនបន្ថែមចំនួនអំពូលភ្លើងបំភ្លឺនិងកន្លែងអង្គុយរង់ចាំ និងរូបភាពរបស់រថយន្តក្រុង SmartBus លេខ902 ។

